# សកម្មភាពសិក្សាមាត្រានៃសេចក្ដីជំនឿ

ជំហានទី ១ ៖ សូមជ្រើសរើសមាត្រានៃសេចក្ដីជំនឿមួយដែលអ្នកចង់សិក្សានៅថ្ងៃនេះ ហើយឆ្លើយសំណួរដូចខាងក្រោមនេះ ៖

- តើសេចក្ដីពិត ឬសេចក្ដីពិតទាំងឡាយដ៏នៅអស់កល្បណាដែលអ្នករៀនពីមាត្រានៃសេចក្ដីជំនឿនេះ ?

- តើការបង្រៀនចេញពីមាត្រានៃសេចក្ដីជំនឿនេះជះឥទ្ធិពលលើទំនាក់ទំនងរបស់អ្នកជាមួយព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទដោយរបៀបណា ?

ជំហានទី ២ ៖ សូមជ្រើសរើសយ៉ាងហោចណាស់ជម្រើសពីរខាងក្រោមនេះ ដើម្បីជួយអ្នកស្វែងយល់បន្ថែមអំពីមាត្រានៃសេចក្ដីជំនឿដែលអ្នកបានជ្រើសរើស ៖

a. *ទន្ទេញ* ។ សូមគិតអំពីគំនិតមួយដើម្បីជួយអ្នកចងចាំមាត្រានៃសេចក្ដីជំនឿរបស់អ្នក ហើយចំណាយពេលទន្ទេញមាត្រានៃសេចក្ដីជំនឿនោះ ។

b. *ស្វែងរកធនធានដែលទាក់ទងគ្នា* ។ សូមស្វែងរកបទគម្ពីរ ឬសេចក្ដីថ្លែងការណ៍មកពីថ្នាក់ដឹកនាំសាសនាចក្រ ដែលទាក់ទងទៅនឹងមាត្រានៃសេចក្ដីជំនឿដែលអ្នកបានជ្រើសរើស ។ អ្នកអាចប្រើឧបករណ៍ដូចជាលេខយោងនៅក្នុងព្រះគម្ពីររបស់អ្នក Topical Guide សេចក្ដីណែនាំដល់បទគម្ពីរទាំងឡាយ ឬមុខងារស្វែងរកនៅលើកម្មវិធីបណ្ណាល័យដំណឹងល្អ ដើម្បីជួយដល់អ្នក ។

c. *បង្កើតតំណាងដែលមើលឃើញ* ។ សូមប្រើសិល្បៈដើម្បីជួយអ្នកប្រាស្រ័យទាក់ទងគ្នា ឬតំណាងឲ្យការបង្រៀនមកពីមាត្រានៃសេចក្ដីជំនឿដែលអ្នកបានជ្រើសរើស ។ ឧទាហរណ៍អាចរួមបញ្ចូលទាំងគំនូរ បណ្ដុំរូបភាព ឬរូបភាពនៃបណ្ដុំវាក្យសព្ទ ឬ meme ។ ( ដោយសារតែលក្ខណៈដ៏ពិសិដ្ឋនៃព្រះអាទិទេព សូមចៀសវាងការគូររូបនៃសមាជិកក្រុមព្រះ ) ។

d. *បង្កើតសាច់រឿង* ។ សូមគិតអំពីស្ថានភាពដែលអ្នក ឬក្មេងជំទង់ផ្សេងទៀតប្រឈមមុខ ឬសំណួរអំពីដំណឹងល្អដែលមាត្រានៃសេចក្ដីជំនឿរបស់អ្នកអាចជួយបាន ។ សូមសរសេរសាច់រឿង ឬសំណួរទាំងឡាយ ហើយពន្យល់ពីរបៀប ឬមូលហេតុដែលសេចក្ដីពិតដែលបានបង្រៀននៅក្នុងមាត្រានៃសេចក្ដីជំនឿអាចជួយបាន ។

e. *ថ្លែងទីបន្ទាល់* ។ សូមសរសេរទីបន្ទាល់របស់អ្នកអំពីសេចក្ដីពិតដែលបានបង្រៀននៅក្នុងមាត្រានៃសេចក្ដីជំនឿរបស់អ្នក ។ សូមពិពណ៌នាអំពីរបៀបដែលការបង្រៀនទាំងនេះបានផ្ដល់ពរដល់ជីវិតរបស់អ្នក ហើយនាំអ្នកឲ្យខិតទៅជិតព្រះ ។

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

© 2024 by Intellectual Reserve, Inc. All rights reserved. PD80007812_258_491-1